# និយមន័យពាក្យថាព្រះពុទ្ធ

**I.អត្ថន័យពាក្យថា«ពុទ្ធ»**

**ពាក្យថា<ពុទ្ធ > មកពី (ពុធ ធាតុ +ត បច្ច័យ)**

១.ព្រះនាមថា«**ពុទ្ធៈ**»ព្រោះទ្រង់ត្រាស់ដឹងនូវសច្ចធម៌។

២.ព្រះនាមថា«**ពុទ្ធៈ**»ព្រោះទ្រង់ញុំាងពួកសត្វឱ្យដឹងតាម។

៣.ព្រះនាមថា«**ពុទ្ធៈ**» ព្រោះទ្រង់ត្រាស់ដឹងធម៌គ្រប់យ៉ាង។

៤.ព្រះនាមថា«**ពុទ្ធៈ**»ព្រោះទ្រង់ឃើញជាក់ច្បាស់នូវធម៌គ្រប់យ៉ាង។

៥.ព្រះនាមថា«**ពុទ្ធៈ**»ព្រោះទ្រង់ដឹងយ៉ាងក្រៃលែង។

៦.ព្រះនាមថា«**ពុទ្ធៈ**» ព្រោះទ្រង់ធ្វើនូវព្រះនិព្វានឱ្យជាក់ច្បាស់។

៧.ព្រះនាមថា«**ពុទ្ធៈ**»ព្រោះទ្រង់អស់នូវអាសវៈកិលេស។

៨.ព្រះនាមថា«**ពុទ្ធៈ**» ព្រោះទ្រង់ប្រាសចាកឧបក្កិលេស។

៩.ព្រះនាមថា «**ពុទ្ធៈ**» ព្រោះទ្រង់ប្រាសចាករាគៈដោយពិតប្រាកដ។

១០.ព្រះនាមថា«**ពុទ្ធៈ**»ព្រោះទ្រង់ប្រាសចាកទោសៈដោយពិតប្រាកដ។

**II.នាមផ្សេងៗដែលគេហៅចំពោះព្រះពុទ្ធ**

**១.** ព្រះពុទ្ធជាម្ចាស់មានព្រះនាមថាព្រះ**«ទសពល»**ព្រោះទ្រង់ទមានកម្លាំងស្មើរនឹងកម្លាំង

ស្តេចដំរីឆ័ទ្ទន្ត១០ក្បាល និងមានកម្លាំងញាណ១០យ៉ាង។

**២**.ព្រះនាមថាព្រះ«**សាស្តា**»ព្រោះទ្រង់ណែនាំបង្ហាត់បង្រៀនសត្វលោកទាំងពួង ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន និងប្រយោជន៍ក្នុងអនាគត និងប្រយោជន៍និព្វាន។

៣.ព្រះនាមថាព្រះ«**សព្វញ្ញូ**» ព្រោះទ្រង់ជាអ្នកដឹងធម៌ទាំងពួង។

៤.ព្រះនាមថា«**ទ្វិបទុត្តម** »ព្រោះព្រះអង្គប្រសើរជាងសត្វជើងពីរគ្រប់ប្រភេទ។

៥.ព្រះនាមថាព្រះ«**មុនិន្ទ**»ព្រោះព្រះអង្គជាធំយ៉ាងក្រៃលែងជាងអ្នកប្រាជ្ញទាំងឡាយ ទើបមានព្រះនាមថា ព្រះ«**មុនិន្ទ**»។

៦.ព្រះនាមថាព្រះ«**ភគវា**»ឬ«**ភគវន្ត**»ឬព្រះ«**ដ៏មានព្រះភាគ**»ព្រោះព្រះអង្គជាអ្នកមានជោគឈ្នះមារសត្រូវគ្រប់យ៉ាងឬទ្រង់ទំលាយរាគៈបាន,ទំលាយទោសៈបាន ,ទំលាយមោហៈបាន និងទំលាយមានះបាន។

**៧+៨**.ព្រះនាមថាព្រះ«**នាថៈ**»ឬព្រះ«**លោកនាថ**»ព្រោះព្រះអង្គទ្រង់ជាទីពឹងរបស់មនុស្សសត្វ  ក្នុងលោក។

៩.ព្រះនាមថា«**ចក្ខុមន្តុ**»ព្រោះទ្រង់មានចក្ខុ គឺព្រះសព្វញ្ញុតញ្ញាណ។

១០.ព្រះពុទ្ធជាម្ចាស់មាននាមថាព្រះ«**អង្គីរសៈ**»ព្រោះព្រះអង្គទ្រង់មានព្រះរស្មីផ្សាយចេញអំពីព្រះវរកាយ។

១១.ព្រះនាមថាព្រះ«**មុនី**»ព្រោះព្រះអង្គព្រះអង្គជាអ្នកប្រាជ្ញដឹងនូវប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ទើបទ្រង់ព្រះនាមថាព្រះ «**មុនី**»។

១២.ព្រះនាមថាព្រះ«**អនធិវរ** »ព្រោះព្រះអង្គទ្រង់ប្រសើរបំផុត, ព្រះអង្គមិនមានបុគ្គលណាប្រសើរជាង។

១៣.ព្រះនាមថាព្រះ«**មហេសី**»ព្រោះព្រះអង្គទ្រង់ស្វែងរកគុណដ៏ធំក្រៃលែង។

១៤.ព្រះនាមថាព្រះ«**វិនាយក**»ព្រោះទ្រង់ជាម្ចាស់ទ្រង់ណែនាំសត្វទៅកាន់ព្រះនិព្វាន។

១៥.ព្រះនាមថាព្រះ«**សមន្តចក្ខុ**»ព្រោះព្រះអង្គទ្រង់មានពុទ្ធញាណដោយជុំវិញគ្រប់ទិសទាំងអស់។

**១៦**.ព្រះនាមថាព្រះ«**សុគត** » ព្រោះទ្រង់មានព្រះញាណដ៏ល្អផូរផង់ និងព្រះអង្គមានដំណើរទៅល្អហើយ។

**១៧**.ព្រះនាមថាព្រះ«**ភូរិបញ្ញា**»ព្រោះទ្រង់មានព្រះបញ្ញាច្រើន, មានបញ្ញា រកទីបំផុតគ្មាន, ព្រះអង្គមានបញ្ញា ទូលំទូលាយដូចផែនដី។

**១៨**.ព្រះនាមថាព្រះ«**មារជិ**»ឬព្រះ«**វិជិតមារ**»ឬព្រះ«**ជិនស្រី**»ព្រោះព្រះអង្គទ្រង់ឈ្នះមារទាំង ៥មានកិលេសមារជាដើមទើបទ្រង់មានព្រះនាមថា "**មារជិ**..."។

**១៩**.ព្រះនាមថាព្រះ«**នរសីហ**» ព្រោះព្រះអង្គជាអ្នកគ្រប់គ្រងមនុស្សសត្វ និងទេវតា។

**២០**.ព្រះនាមថាព្រះ«**នរវរ**» ព្រោះព្រះអង្គទ្រង់ប្រសើរជាងទេវតា និងមនុស្ស។

**២១**.ព្រះនាមថាព្រះ«**ធម្មរាជា**»ព្រោះព្រះអង្គទ្រង់ត្រេកអរនូវធម៌,ទ្រង់ញុំាងពពួកសត្វឱ្យត្រេកអរដោយព្រះធម៌។

**២២**.ព្រះនាមថាព្រះ«**មហាមុនិ**»ឬព្រះ«**មហាមុនី**»ព្រោះព្រះអង្គទ្រង់ជាអ្នកប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ៥។

**២៣**.ព្រះនាមថាព្រះ«**ទេវ ទេវៈ**»ព្រោះព្រះអង្គជាទេវតារបស់ទេវតា។

**២៤**.ព្រះនាមថាព្រះ«**លោកគរុ**»ឬព្រះ«**លោកវិទូ**»ព្រោះព្រះអង្គជាគ្រូរបស់សត្វលោក។

**២៥**.ព្រះនាមថាព្រះ«**ធម្មស្សាមី**»ព្រោះព្រះអង្គជាម្ចាស់របស់ធម៌។

**២៦**.ព្រះនាមថាព្រះ«**តថាគត**»ព្រោះព្រះអង្គជាសច្ចវាទី,ជាអ្នកពោលពាក្យពិត,ពោលពាក្យត្រឹមត្រូវ។

**២៧**.ព្រះនាមថា«**សយម្ភូ**»ព្រោះព្រះអង្គ ត្រាស់ដឹងញេយ្យធម៌ដោយព្រះអង្គឯង។

**២៨**.ព្រះនាមថា«**សម្មាសម្ពុទ្ធ**»ឬព្រះ«**សព្វញ្ញូពុទ្ធ**»ព្រោះព្រះអង្គទ្រង់ត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឯង។

២៩.ព្រះនាមថាព្រះ«**បវរបញ្ញា**»ព្រោះព្រះអង្គទ្រង់មានព្រះបញ្ញាប្រសើរបំផុត។

៣០.ព្រះនាមថាព្រះ«**នាយក**»ព្រោះ ព្រះអង្គជាអ្នកដឹកនាំ។

៣១.ព្រះនាមថា«**ជិនៈ**»ឬព្រះ«**ជិនស្រី**»ព្រោះព្រះអង្គជាអ្នកឈ្នះមារទាំង៥ គឺទេវបុត្តមារ, កិលេសមារ, អភិសង្ខារមារ, ខន្ធមារ, និងមច្ចុមារ។

គ.**ព្រះនាមរបស់ព្រះពុទ្ធជាម្ចាស់ចំពោះអង្គបច្ចុប្បន្ន មានបន្ថែមទៀត ៧ស័ព្ទ៖**

**៣២.**ព្រះនាមថា«**សក្ក**»ប្រែថា ព្រះ«**ទ្រង់អាច**»។ព្រះអង្គអាចឈ្នះមារទាំង៥ ព្រះនាមថា "**សក្កៈ**" ព្រោះព្រះអង្គអាចកាត់ផ្ដាច់នូវធម្មទំនៀមរបស់មនុស្សលោក, ព្រះអង្គអាចរៀបការជាមួយបងស្រី ប្អូនស្រី របស់ខ្លួនបាន ទើបឈ្មោះថា "**សក្កៈ**" សំដៅដល់បុព្វក្សត្ររបស់សក្យវង្ស។

៣៣.ព្រះនាមថា«**សិទ្ធត្ថ**»ព្រោះព្រះអង្គទ្រង់ធ្វើប្រយោជន៍ឱ្យសម្រេចដល់សត្វលោក, ទើបទ្រង់ព្រះនាមថា "**សិទ្ធត្ថ**" ។

៣៤.ព្រះនាមថា«**សុទ្ធោទនិ**»ព្រោះព្រះអង្គជាព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនៈ។

៣៥.ព្រះនាមថា«**គោតម**»ព្រោះព្រះអង្គជាព្រះឱរសរបស់ត្រកូលដែលជាសិស្សរបស់

កបិលតាបស គោតមគោត្រ ទើបមានព្រះនាមថា "**គោតម**"។

៣៦.ព្រះនាមថា«**សក្យសីហ**»ព្រោះព្រះអង្គប្រសើរជាងស្ដេចសក្យគ្រប់ព្រះអង្គ។

៣៧.ព្រះនាមថា«**សក្យមុនិ**»ឬព្រះ«**សក្យមុនី**»ព្រោះព្រះអង្គជាអ្នកប្រាជ្ញបួសចេញពីត្រកូលសក្យ។

៣៨.ព្រះនាមថា«**អាទិច្ចពន្ធុ**» ព្រោះព្រះអង្គទ្រង់មានក្រសែព្រះរស្មីផ្សាយទៅដល់វិមានរបស់សុរិយទេវបុត្រ ឬទ្រង់ជាញាតិរបស់ព្រះអាទិត្យ ទើបទ្រង់ព្រះនាមថា " **អាទិច្ចពន្ធុ**"។

## <u>គាថាបញ្ចប់</u>

១/ ពុទ្ធោ ទសពលោ សត្ថា

សព្វញ្ញូ ទ្វិបទុត្តមោ

មុនិន្ទោ ភគវា នាថោ

ចក្ខុអង្គីរសោ មុនិ។

២/ លោកនាថោនធិវរោ មហេសិ ច

វិនាយកោ សមន្តចក្ខុ សុគតោ

ភូរិបញ្ញោ ច មារជិ។

៣/ នរសីហោ នរវរោ ធម្មរាជា

មហាមុនិ ទេវទេវោ លោកគរុ

ធម្មស្សាមី តថាគតោ។

៤/ សយម្ភូសម្មាសម្ពុទ្ធោ វរបញ្ញោ

ច នាយកោ ជិនោ សក្កោ តុ

សិទ្ធត្ថោ សុទ្ធោទនិ ច គោតមោ។

៥/ សក្យសីហោ តថា សក្យមុនិ អាទិច្ចពន្ធុ ច៕

## <u>ចប់</u>

ថ្ងៃពុធ ទី៨ ខែកក្កដា ឆ្នាំ២០២០វត្តខេមរារាម,ទីក្រុងសាន់ហូហ្សេ,រដ្ឋកាលីហ្វ័ញ៉ា,សហរដ្ឋអាមេរិក

ប្រែសម្រួលដោយភិក្ខុ **ដួង ចន្ទ** និងកែសម្រួល ដោយភិក្ខុ **សឿង វុទ្ធី**